# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 125

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

## ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ការអភិវឌ្ឍន៍កម្មវិធិសិក្សា និង បង្កើនសមត្ថភាព របស់មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/10/14

កាលបរិច្ឆេទបញ្ចប់គម្រោង 01/09/16

៣. ចំណាយគម្រោងសរុប $185,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

RESPONSIBLE UNIT

អង្គភាពទទួលខុសត្រូវ

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

### ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៏វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី Livestock

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

**រាជធានីភ្នំពេញ,**

**១៣. គោលបំណងរបស់គម្រោង** ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

- **ធ្វើបញ្ជីសារពើភ័ណ្ឌពីសមត្ថភាព និងសម្ភារបង្រៀន**
- **កែសម្រួលកម្មវិធីសិក្សារបស់មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វរួមគ្នាជាមួយ OIE**
- **កម្មវិធីកសាងសមត្ថភាព រួមមានការអនុវត្តន៍ផែនការ របស់មហាវិទ្យាល័យ**
- **ចុះបញ្ជីជំនួយលើការបង្រៀនរបស់មហាវិទ្យាល័យ ព្រមទាំងសម្ភារ និងឧបករណ៍លើការរៀនសូត្រ**

**១៤. ការពិពណ៌នាអំពីគម្រោង** ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

ការចិញ្ចឹមសត្វជាផ្នែកសំខាន់មួយសម្រាប់វិស័យកសិកម្ម
ហើយការបង្កើនបច្ចេកទេសចិញ្ចឹមសត្វស្ថិតនៅក្រោមមុំមួយនៃយុទ្ធសាស្ត្រចតុកោណក្នុង ការផ្តល់ការងារ ភាពស្មើភាពនិងប្រសិទ្ធភាព
ក្នុងការជំរុញវិស័យកសិកម្ម។ យុទ្ធសាស្ត្រចតុកោណបានសង្កត់ធ្ងន់លើការជំរុញវិស័យចិញ្ចឹមសត្វ រួមបញ្ចូលសុវត្ថិភាព អាហារ
និងអនាម័យខ្ពស់។ ការចិញ្ចឹមសត្វដែលមានលក្ខណៈប្រសើរមួយបានចូលរួមយ៉ាងពេញទំហឹងក្នុងការចូលរួមកាត់បន្ថយភាពក្រីក្រ
សន្តិសុខស្បៀង និង ចេរភាពនៃផលិតកម្មអាហារ។ ទោះជាយ៉ាងនោះក្តីសមាហរណកម្ម និងការប្រែប្រួលអាកាសធាតុ
បានផ្តល់ការគំរាមកំហែងថ្មីក្នុងការការពារជំងឺ ការរាតត្បាតជំងឺ ទំនងជាសាយភាយតាមរយៈការចូលដល់តំបន់ថ្មីៗ
ដែលធ្វើអោយជះឥទ្ធិពលអវិជ្ជមានទៅលើការបរិភោគអាហារ។ ដើម្បីផ្តល់ការជឿជាក់ខ្ពស់លើវិស័យចិញ្ចឹមសត្វ
ការយកចិត្តទុកដាក់លើសុខភាពសត្វត្រូវតែគិតពិចារណាយ៉ាងត្រឹមត្រូវ។ នៅឆ្នាំ២០១១អង្គការ OIE
បានវិភាគទៅលើការខ្វះខាតនៃអ្នកផ្តល់សេវាកម្មបសុពេទ្យ
បានបង្ហាញថាគុណភាពនៃអ្នកផ្តល់សេវាកម្មបសុពេទ្យគួរតែត្រូវបានធ្វើអោយល្អនិងមានសមត្ថភាពខ្ពស់ជាពិសេសសម្រាប់និស្សិតដែល
បញ្ចប់ផ្នែកពេទ្យសត្វ។
ការបណ្តុះបណ្តាលផ្នែកបសុពេទ្យអោយមានគុណភាពខ្ពស់គឺជាតំរូវការចាំបាច់និងសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពផ្នែកសេវាកម្មបសុពេទ្យ ដូច្នេះហើយបង្កើន
គុណភាពបណ្តុះបណ្តាលបសុពេទ្យគឺជាផែនការណ៍ចំបងមួយដែលចូលរួមក្នុងការបំរើដល់វិស័យបសុពេទ្យរបស់រដ្ឋាភិបាល។
ក្នុងបរិបទនេះការបណ្តុះបណ្តាល បសុពេទ្យ នៅក្នុងប្រទេសកម្ពុជាត្រូវតែបានពង្រឹង
និងកែលំអរអោយប្រសើរសម្រាប់បង្កើតអ្នកជំនាញបសុពេទ្យ។
សាកលវិទ្យាល័យភូមិន្ទកសិកម្មបានបង្កើតនៅឆ្នាំ១៩៦៤ ជាសាកលវិទ្យាល័យឈានមុខសម្រាប់វិស័យកសិកម្មនៅក្នុងប្រទេសកម្ពុជា។
បេសកម្មរបស់សាកល វិទ្យាល័យគឺចូលរួមក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម និងវិស័យទាក់ទងផ្សេងទៀត
ហើយជានាចេរភាពនៃការប្រើប្រាស់ធនធានធម្មជាតិដោយផ្តល់ការកម្មវិធី អប់រំកំរិត ខ្ពស់ ការស្រាវជ្រាវ និងផ្សព្វផ្សាយ
ទៅតាមគោលដៅអភិវឌ្ឍន៍កំរិតជាតិ និងអន្តរជាតិ និងតំរូវការទីផ្សារការងារ។ មហាវិទ្យាល័យវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ
ស្ថិតនៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ មហាវិទ្យាល័យមានតួនាទីផ្តល់ការបណ្តុះបណ្តាលលើវិស័យវិទ្យាសាស្ត្រសត្វ
និងវេជ្ជសាស្ត្រសត្វ។ មហាវិទ្យាល័យបាន បែងចែកជាពីរផ្នែកគឺ ផ្នែកវិទ្យាសាស្ត្រសត្វ និងផ្នែកវេជ្ជសាស្ត្រសត្វ។
ផ្នែកវេជ្ជសាស្ត្រសត្វបានផ្តល់ការបណ្តុះបណ្តាល៤ឆ្នាំលើបរិញ្ញាបត្រវេជ្ជសាស្ត្រសត្វ។ ទោះបីជា យ៉ាងណាក៏ដោយ
សាកលវិទ្យាល័យបានផ្តោតសំខាន់លើការបណ្តុះបណ្តាលផ្នែកវិទ្យាសាស្ត្រសត្វ
ចំណែកឯការបណ្តុះបណ្តាលផ្នែកវេជ្ជសាស្ត្រសត្វមិនទាន់បាន គ្រប់គ្រាន់តាមកំរិតស្តង់ដារនៅឡើយ។ នៅឆ្នាំ ២០១៣
រាជរដ្ឋាភិបាលបានសំរេចបំបែកមហាវិទ្យាល័យជាពីរគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រសត្វ និង មហាវិទ្យាល័យ វេជ្ជសាស្ត្រសត្វ។
មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វមានបេសកម្ម បង្កើតនិងអនុវត្តន៍កម្មវិធីសិក្សារយៈពេល៦ឆ្នាំ សម្រាប់ថ្នាក់ DVM
ដែលនឹងអាចស្របតាមសកល វិទ្យាល័យក្នុងបណ្តាប្រទេសក្នុងសមាគមប្រជាជាតិអាស៊ី (Asian Association of Veterinary
School)។ ដោយសារតែមហាវិទ្យាល័យទើបតែបង្កើតថ្មី មហាវិទ្យាល័យ បានជួបប្រទះបញ្ហាប្រឈមជាច្រើនដូចជា
កម្មវិធីសិក្សាទាបបើប្រៀបទៅនឹងកំរិតអន្តរជាតិ សមត្ថភាពគ្រូបង្រៀននៅមានកំរិត កង្វះខាតសម្ភារៈសិក្សា និងកង្វះខាត
ពត៌មានវិទ្យាសាស្ត្រដែលទាក់ទងសុខភាពសត្វសម្រាប់និស្សិតប្រើប្រាស់ និងការអនុវត្តន៍ផ្ទាល់នៅមានកំរិត។ ដូច្នេះការឧបត្ថម្ភនានា
គឺទាមទារចាំបាច់សម្រាប់ដោះ ស្រាយបញ្ហាប្រឈមទាំងនេះ។ អង្គការ FAO
បានចាប់អារម្មណ៍លើការពង្រឹងសមត្ថភាពរបស់មន្ត្រីក្នុងមហាវិទ្យាល័យ ហើយក៏ដូចជាផ្តល់ដល់និស្សិតដែលបញ្ចប់
ការសិក្សានូវជំនាញខ្ពស់លើផលិតកម្មនិងសុខភាពសត្វ។

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ដើម្បីបង្កើនផលិតកម្មសត្វ វាទាមទារសំខាន់លើការធ្វើអោយប្រសើរលោះងនូវការបង្កាត់ពូជល្អៗ ចំណី និងការថែទាំ ការការពារ និងការទប់ស្កាត់ជម្ងឺសត្វ ក៏ដូចជាការកែលំអរសុខមាលភាពសត្វ ដែលចូលរួមក្នុងការកាត់បន្ថយការឆ្លងនៃជម្ងឺឆ្លងពីមនុស្សទៅសត្វ និងពីសត្វទៅមនុស្សផ្សេងៗ។ យុទ្ធសាស្ត្រមួយសម្រាប់

វិស័យនេះគួរតែរួមបញ្ចូលការយកចិត្តទុកដាក់ជាពិសេសសម្រាប់អ្នកផលិតខ្នាតតូច និងការផ្សព្វផ្សាយការគ្រប់គ្រងល្អៗដែលឆ្លើយតបទៅបែបប្រពលវប្បកម្ម និងការបង្កើនប្រសិទ្ធភាពនៃការចិញ្ចឹមសត្វ។ រាល់ការលើកឡើងខាងលើទាំងអស់នេះ យុទ្ធសាស្ត្រសម្រាប់ផលិតកម្មសត្វ និងការគ្រប់គ្រងសុខភាពសត្វ ទាមទារ សមត្ថភាពធនធានមនុស្សដែលមានសមត្ថភាពជំនាញខ្ពស់ក្នុងការអនុវត្តន៍កម្មវិធីចិញ្ចឹមសត្វ។

OIE បានបង្កើតសមត្ថភាពអប្បរមា (ជំនាញ និងការអនុវត្តន៍រោគរាតត្បាតជំងឺ ជំងឺឆ្លងពីប្រទេសមួយទៅប្រទេសមួយ ជំងឺឆ្លងសត្វទៅមនុស្ស ជំងឺថ្មី និងជំងឺឆ្លាប់ផ្ទុះ ឡើងវិញ  កម្មវិធីការពារ និងទប់ស្កាត់ជំងឺ សុវត្ថិភាពអាហារ ផលិតផលសាច់សត្វ សុខមាលភាពសត្វ ច្បាប់បសុពេទ្យ ដំណើរការបញ្ជាក់វិញ្ញាបនបត្រ និងជំនាញ ទំនាក់ទំនងផ្សេងៗ) ដែលតំរូវផ្តល់ដល់និស្សិតដែលបានបញ្ចប់បសុពេទ្យអាចមានសមត្ថភាពគ្រប់គ្រាន់ដើម្បីចូលរួមផ្តល់សេវាកម្មបសុពេទ្យកំរិតថ្នាក់ជាតិ(ទាំងរដ្ឋ និងឯកជន)។

សមត្ថភាពអប្បរមានេះនឹងត្រូវផ្តល់ដល់អ្នកដែលបានបញ្ចប់ការសិក្សាផ្នែកបសុពេទ្យក្នុងការជំរុញសុខភាពសាធារណៈអោយប្រសើរ និងផ្តល់ការបណ្តុះ បណ្តាលកំរិតខ្ពស់ដល់បសុពេទ្យទាំងនោះដែលពួកគេអាចទទួលបានជំនាញមួយសម្រាប់បំរើដល់រដ្ឋ និងឯកជនក្នុងការផ្តល់សេវាកម្មបសុពេទ្យរបស់ជាតិ។

ការប្រឈមដែលកំពង់ជួបប្រទះក្នុងការបណ្តុះបណ្តាលផ្នែកបសុពេទ្យក្នុងប្រទេសកម្ពុជាទាមទារការចាប់អារម្មណ៍ជាពិសេសលើកង្វះខាតវិធីសាស្ត្រនៃការបង្រៀន និងធនធានដែលសម្រួលដល់ការបង្រៀន។

យុទ្ធសាស្ត្រមួយក្នុងការធ្វើអោយប្រសើរលើការបណ្តុះបណ្តាលបសុពេទ្យនៅកម្ពុជាគួរតែត្រូវបង្កើតឡើងតាមរយៈ ការបង្កើតនិងអនុវត្តន៍កម្មវិធិសិក្សាដែលល្អ និងការផ្តល់សម្ភារៈបរិក្ខាសម្រាប់ផ្គត់ផ្គង់ដល់ការអនុវត្តន៍កម្មវិធិសិក្សានេះ។ ការជំរុញការបណ្តុះបណ្តាលបសុពេទ្យនៅ នៅកំរិតសាកលវិទ្យាល័យទាមទារតាមដំណាក់កាល និងកំរិតនៃការជ្រោមជ្រែងពីមហាវិទ្យាល័យ ហេដ្ឋារចនាសម្ព័ន និងធនធានផ្សេងៗ។ វាទាមទារការផ្លាស់ប្តូរជាប្រចាំលើវិធិសាស្ត្របង្រៀនជាមួយប្រទេសផ្សេងៗ និងការឈានទៅដល់ការអនុវត្តន៍ផ្ទាល់ជាប្រចាំរបស់និស្សិត។ FAO អាចរៀបចំសកម្មភាពទាំងនេះ និងពាំនាំ

សកម្មភាពទាំងនេះជាមួយគ្នាដើម្បីទទួលបានការអភិវឌ្ឍន៍មួយសម្រាប់ការបណ្តុះបណ្តាលបសុពេទ្យនៅកម្ពុជា។ FAO អាចជួយក្នុងការរៀបចំចំណេះដឹងទាំងនេះ ទៅជាសកម្មភាព និងអាចតភ្ជាប់ជំនាញនេះក្នុងការចាប់ផ្តើមទៅថ្នាក់ជាតិ តំបន់ និងសកលជាពិសេសការបណ្តុះបណ្តាលបសុពេទ្យ អោយទៅជាទំរង់ជាក់ស្តែងមួយ ដែលអាចជួយដល់កសិករ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

អ្នកពាក់ព័ន្ធ និងអ្នកទទួលផលផ្ទាល់មានដូចជាមន្ត្រីគ្រូបង្រៀនដែលបំរើការនៅមហាវិទ្យាល័យ និងនិស្សិតដែលកំពង់សិក្សានៅមហាវិទ្យាល័យ វេជ្ជសាស្ត្រសត្វទាំងអស់។ សមត្ថភាពបង្រៀននឹងត្រូវបង្កើន ហើយដែលអាចផ្តល់ដល់និស្សិតដែលបានសិក្សានៅទីនោះមានការកើនឡើងនូវជំនាញផ្នែក វេជ្ជសាស្ត្រ សត្វបានត្រឹមត្រូវ ហើយក្រោយពេលបញ្ចប់ការសិក្សាអាចផ្តល់ និស្សិតទាំងនោះអាចសេវាកម្មយ៉ាងល្អសម្រាប់អ្នកចិញ្ចឹមសត្វទាំងអស់ក្នុងប្រទេស។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | គ្មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | មិនទានចាប់ផ្តើម |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងចុលរួមពង្រឹងសមត្ថភាពរបស់មន្ត្រី និងនិស្សិតមហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ ព្រមទាំងធនធានមនុស្សរបស់ ប្រទេសកម្ពុជា ដើម្បីបង្កើត និងអនុវត្តកម្មវិធីគ្រប់គ្រងផលិតកម្ម និងសុខភាពសត្វ។

១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
| --- | --- | --- |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**តួនាទីរបស់ស្ត្រីមានសារៈសំខាន់ណាស់សម្រាប់បំរើដល់វិស័យចិញ្ចឹមសត្វជាពិសេសសត្វតូចៗដូចជាមាន់ទាជាដើម។ ការចុះឈ្មោះចូលរៀន និងការ បញ្ចប់ការសិក្សារបស់និស្សិតជានារីសម្រាប់មហាវិទ្យាល័យ វេជ្ជសាស្ត្រសត្វ ពិតជាមាន សារៈសំខាន់ ប៉ុន្តែគម្រោងមិនមានឥទ្ធិពលលើចំនួននិស្សិតជានារីសម្រាប់ មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វនោះទេ។ គម្រោងបានធានាការទទួលបានស្មើភាពគ្នារាល់សកម្មភាពដែលបានអនុវត្តក្នុងគម្រោងរវាងបុគ្គលិកទាំងពីរភេទក្នុង និងនិស្សិតទាំងពីរភេទមហាវិទ្យាល័យ។ ដោយសារតែភាគច្រើនស្ត្រីជាអ្នកដែលមើលថែសត្វដោយផ្ទាល់ ជាក់ស្តែង ការមើលថែមាន់ ដូច្នេះការជះឥទ្ធិពលរយៈពេលយូរ អង្វែងដល់អ្នកដែលមិនទទួលផលផ្ទាល់សម្រាប់ស្ត្រីអាច កើតមាន ដូចជាទៅលើកាត់បន្ថយនៃហានិភ័យជំងឺឆ្លងពីសត្វមកមនុស្សដែលអាចកើតមានលើស្ត្រី ។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**មន្ត្រី សាស្ត្រាចារ្យមហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការពន្យាពេលក្នុងការអនុវត្តគម្រោង។)

**គំរោងត្រូវបានពន្យាដោយសារតែការអនុវត្តន៍ជាក់ស្តែងបានធ្វើនៅដើមឆ្នាំ២០១៥។ មហាវិទ្យាល័យដើរតួសំខាន់ជាដៃគូក្នុងការអនុវត្តន៍គម្រោងតាមរយៈការសម្របសម្រួលនានាជាមួយអង្គការFAO ប្រចាំកម្ពុជា។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**ថវិកាគ្រប់គ្រងដោយ FAO ហើយមហាវិទ្យាល័យវេជ្ជសាស្ត្រជាអ្នកអនុវត្ត**

# ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2015 | | 2016 | 2017 | 2018 | 2019 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2017-2019 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2015 | | 2016 | 2017 | 2018 | 2019 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2017-2019 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| FAO | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: